ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២០៥ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការបំពេញបន្ថែមឯកសណ្ឋាន សញ្ញាសក្តិ និងមួក របស់អគ្គនាយកដ្ឋានកម្ពុជា ត្រួតពិនិត្យទំនិញនីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល "

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥/ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៤៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពី ឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាក សញ្ញាសំគាល់របស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ "កាំកុងត្រូល"
- បានឃើញអនុក្រឹត្យលេខ ១៤៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៧ ស្តីពីការបំពេញបន្ថែមឯកសណ្ឋាន របស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ "កាំកុងត្រូល"
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីការដំឡើងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) អោយទៅជាអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ចំណុះក្រសួងពាណិជ្ជកម្ម
- តាមសំណើរបស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រា ១ :**

បំពេញបន្ថែម អនុក្រឹត្យលេខ ១៤៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៧ ស្តីពីការបំពេញបន្ថែមឯកសណ្ឋាន របស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ "កាំកុងត្រូល" និងដាក់អោយប្រើប្រាស់ឯកសណ្ឋាន សញ្ញាសក្តិ និងមួក សំរាប់អគ្គនាយក-អគ្គនាយករង នៃអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ "កាំកុងត្រូល" ។

**មាត្រា ២ :**

ខ្លឹមសារដែលត្រូវបំពេញបន្ថែម ត្រូវបានកំណត់ដូចតទៅ ÷

**១- ឯកសណ្ឋាន :** មានបីប្រភេទ ដូចមានគំរូក្នុងឧបសម្ព័ន្ធ

**<u>ឯកសណ្ឋានសំរាប់ការងារ</u>**

- ខោ ជើងវែង ពណ៌ពងក្រសារ ផលិតអំពីសាច់ក្រណាត់តេហ្គាលខ្សែន ចង្កេះតម្លេរ បង្កប់ ជីបភ្លី ខាងមុខពីរ មានហោប៉ៅបី "ហោប៉ៅខាងក្រោយមួយ ដេរបង្កប់មានគំរប រាងស្លឹកពោធិ និងហោប៉ៅពីរ ទៀតនៅចំហៀង ដេរបង្កប់តាមថ្នេរ" ។
- អាវ អាវដៃខ្លី មានពណ៌ និងសាច់ក្រណាត់ដូចខោ កបើក ថ្នេរឌុប ប៊ូលស្មា ជីប ចង្កេះ មានហោប៉ៅបួន "ហោប៉ៅពីរខាងលើដេរប៉ះ បត់ផ្នត់កណ្តាល មានគំរបរាងស្លឹកពោធិ ហោប៉ៅផ្លាកពីរខាងក្រោម ដេរប៉ះមានគំរបរាងស្លឹកពោធិ" ឡេវមុខ និងហោប៉ៅ រូបព្រះសង្ហា ពណ៌មាស ។

**<u>ឯកសណ្ឋានសំរាប់ពិធីការ</u>**

ប្រភេទអាវធំដៃវែង ផលិតអំពីសាច់ក្រណាត់តេហ្គាខ្សែន ពណ៌ពងក្រសារចាស់ កបើក ថ្នេរឌុប ប៊ូលស្មា ជីបភ្លីខាងមុខពីរ មានឡេវធំពីក្រោមរហូតដល់លើពណ៌ទឹកមាស ហោប៉ៅបួន (ហោប៉ៅពីរ ខាងលើ បត់ផ្នត់កណ្តាល មានគំរបរាងស្លឹកពោធិ ដោយមានឡេវធំពណ៌មាស ហោប៉ៅពីរទៀត នៅក្រោម មានគំរបរាងចតុកោណកែង ដោយមាន ឡេវធំពណ៌មាស ។ ផ្នែកខាងក្រោយមាន ជីបភ្លីចំនួនពីរ ឆ្វេងមួយ ស្តាំមួយ និងមានរែកចំកណ្តាលនៃអាវ ។

**<u>ឯកសណ្ឋានសំរាប់បំពេញប្រតិបត្តិការ នៅតាមព្រំដែន</u>**

ប្រភេទអាវដៃវែងពាក់ខាងក្រៅ ផលិតអំពីសាច់ក្រណាត់មួយរយភាគរយកូតុង មានពណ៌ខ្មៅ ប្រផេះ កបើក ថ្នេរឌុប មានឡេវរ៉ូតពីក្រោមរហូត ដល់លើ ផ្នែកខាងក្រោមមានក្រវ៉ាត់ចង្កេះសងខាង និង មានហោប៉ៅបួន (ហោប៉ៅពីរនៅខាងក្រោម ដេរបង្កប់តាមថ្នេរ ឆ្វេងមួយ ស្តាំមួយ និងហោប៉ៅពីរទៀត នៅខាងក្នុងអាវ ផ្នែកមុខ ឆ្វេងមួយ ស្តាំមួយ) ។ ផ្នែកមុខស្តាំដៃ ខាងលើ មានបាក់អក្សរថា " កាំកុងត្រូល " ពណ៌ពងក្រសារ និងផ្នែកខាងក្រោយអាវ មានបាក់អក្សរឡាតាំងរាងកោងបន្តិចចំកណ្តាល ថា "CAMCONTROL" ពណ៌ពងក្រសារ ។

២- សញ្ញាសក្តិ :

- សញ្ញាសក្តិស្មា មានពីរថ្នាក់ ដូចមានគំរូក្នុងឧបសម្ព័ន្ធ

• **ថ្នាក់អគ្គនាយក :**

មានផ្ទៃពណ៌ខៀវទឹកប៊ិច ក្បាច់ភ្ញីទេស ព័ទ្ធជុំវិញ ពណ៌មាស ចារឹកអក្សរ "កាំកុងត្រូល" ពណ៌មាស និងក្បាច់ទ្រូខាងក្រោម រូបសញ្ញាសំគាល់របស់អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរណ-អាហរណ និងបង្ក្រាបការ ក្លែងបន្លំ (កាំកុងត្រូល) រាងពងក្រពើ "ពណ៌មាស" ដែលនៅចំកណ្តាល និងមានរូបព្រះសង្ហា "ពណ៌មាស" នៅខាងចុងនៃសញ្ញាសក្តិ ។

• **ថ្នាក់អគ្គនាយករង :**

មានផ្ទៃពណ៌ខៀវទឹកប៊ិច ក្បាច់អង្គរ ព័ទ្ធជុំវិញ ពណ៌មាស ចារឹកអក្សរ "កាំកុងត្រូល" ពណ៌មាស និងក្បាច់ទ្រូខាងក្រោមរូបសញ្ញាសំគាល់របស់ អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរណ-អាហរណ និងបង្ក្រាបការ ក្លែងបន្លំ (កាំកុងត្រូល) "ពណ៌មាស" ព័ទ្ធអមដោយភ្ញីផ្កា និងរូបព្រះសង្ហា "ពណ៌មាស" នៅខាងចុងនៃសញ្ញាសក្តិ ។

៣- មួកៈ

- មួកកាស្កែត មានពីរថ្នាក់ ដូចមានគំរូក្នុងឧបសម្ព័ន្ធ

• **ថ្នាក់អគ្គនាយក :**

មួកកាស្កែតធ្វើពីក្រណាត់ពណ៌ដូចសំលៀកបំពាក់ ដែលផ្នែកខាងមុខ លើកណ្តាប់វ័ណ្ណ មានភ្ជាប់រូបព្រះសង្ហាពណ៌មាស ទំហំកំពស់ ៧,៨ ស.ម ទទឹង ៦,៨ ស.ម បែកខាងក្រោមនៃជើងមួក និងក្រោមព្រះសង្ហា មានក្បាច់ភ្ញីទេស ចាក់ពណ៌មាស ដល់ជើងមួក និងខាងក្រោមក្បាច់ មានចាក់វ័ណ្ណពណ៌មាស ពីលើក្រណាត់ខ្សែន ពណ៌ខៀវទឹកប៊ិចព័ទ្ធជុំវិញ ព្រមទាំងនៅចុងខ្សែវ័ណ្ណ ទាំងពីរខាង ភ្ជាប់ដោយខ្សៀវរូបព្រះសង្ហា ពណ៌មាស ។ ខាងក្រោមនៃចាក់វ័ណ្ណបែកខាងមុខ មានក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានចាក់ក្បាច់ភ្ញីទេសចាក់ពណ៌មាស ទម្រង់ស្វែងក្របីធំ ដល់ជើងមួក ។

• **ថ្នាក់អគ្គនាយករង :**

មួកកាស្កែតធ្វើពីក្រណាត់ពណ៌ដូចសំលៀកបំពាក់ ដែលផ្នែកខាងមុខ លើកណ្តាប់វ័ណ្ណ មានភ្ជាប់រូបព្រះសង្ហាពណ៌មាស ទំហំកំពស់ ៧,៨ ស.ម ទទឹង ៦,៨ ស.ម បែកខាងក្រោមនៃជើងមួក និងក្រោមព្រះសង្ហា មានចាក់វ័ណ្ណពណ៌មាស ពីលើក្រណាត់ខ្សែន ពណ៌ខៀវទឹកប៊ិចព័ទ្ធជុំវិញ ព្រមទាំងនៅចុងខ្សែវ័ណ្ណ ទាំងពីរខាង ភ្ជាប់ដោយខ្សៀវរូបព្រះសង្ហា ពណ៌មាស ។ ខាងក្រោមនៃចាក់វ័ណ្ណបែកខាងមុខ មានក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានចាក់ក្បាច់ភ្ញីទេសចាក់ពណ៌មាស ទម្រង់ស្វែងក្របីធំ ដល់ជើងមួក ។

គ. សំរាប់បំពេញប្រតិបត្តិការ នៅតាមព្រំដែន មានដូចមានគំរូក្នុងឧបសម្ព័ន្ធ

ម្ជុលកាតិប ធ្វើពីគ្រឿងរោហធាតុលាយពេញឡេន ពណ៌ខ្មៅប្រផេះ ដែលផ្នែកខាងមុខ មានរូបព្រះសង្ហា " ពណ៌មាស " មានត្បូងពណ៌ដូចត្បូងមរកត ដោយមានក្បាច់ភ្ញីទេស ខិនពណ៌មាស ព័ទ្ធជុំវិញគែមប៊ូតុង ។ ផ្នែកចំហៀង ខាងឆ្វេង មានចំលាក់អក្សរ ថា " កាំកុងត្រូល " ពណ៌មាស និងផ្នែកចំហៀងខាងស្តាំ មានចំលាក់អក្សរឡាតាំង ថា " CAMCONTROL " ពណ៌មាស ។

**មាត្រា ៣ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៨

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីដើម្បីចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ កាលប្បវត្តិ